**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១០៩ /០០៩ /២០០៦

ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ :០៨១/០០៨/២០០៦ កបធ.ច

ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៣៩/០០១/២០០០ កបធ.ច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/០៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតលេខ ៩១៦ រស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ វេលាម៉ោង ១០ និង ១៣ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី ២ ឃ្លាទី ១ ចែងថា " *បទបញ្ញត្តិផ្ទៃក្នុងរដ្ឋសភា បទបញ្ញត្តិផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសអោយប្រើ* " ។ សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា...

លេខ៩១៦រស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០០៦ វេលាម៉ោង១០និង១៣ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំឱ្យពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន ។

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ ។
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរដ្ឋសភា នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្រប កាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។៖

រាជធានីភ្នំពេញថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**ប៊ិន ឈិន**